ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ២ រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលកិច្ចប្រជុំបូកសរុបការងារ
## របស់ក្រុមការងារបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)
## លើការវាយតម្លៃលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា

នាព្រឹកថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំបូកសរុប ***“លទ្ធផលនៃការវាយតម្លៃលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា សម្រាប់ឆ្នាំ ២០២៣ និង ២០២៤”*** ដោយក្រុមបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយលោក **Davide Furcer** ប្រធានក្រុមបេសកកម្ម ។ កិច្ចប្រជុំមានការអញ្ជើញចូលរួមពីលោក **Jochen M. Schmitmann** តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំតំបន់នៅកម្ពុជា, វៀតណាម និងឡាវ ផងដែរ ។

លោក **Davide Furcer** ប្រធានក្រុមបេសកកម្ម បានជម្រាបជូនពីលទ្ធផលនៃការវាយតម្លៃរបស់ IMF មកលើស្ថានភាពសេដ្ឋកិច្ចកម្ពុជាថាមាន ***“កំណើនប្រមាណ ៥,៣% ក្នុងឆ្នាំ ២០២៣”*** នេះ ដែលគាំទ្រដោយការងើបឡើងវិញនៃវិស័យទេសចរណ៍ និងវិស័យសេវាកម្មនានា រួមផ្សំនឹងកំណើនប្រសើររឹងមាំនៃការនាំចេញផលិតផលកម្មន្តសាលមិន-មែនកាត់ដេរ បើទោះបីជាការនាំចេញផលិតផលកាត់ដេរមានភាពថមថយ ស្របពេលវិស័យសំណង់ និងអចលនទ្រព្យនៅមានកំណើនយឺតក៏ដោយ ។

អត្រាអតិផរណាត្រូវបានវាយតម្លៃថានឹងថមថយក្នុងអត្រា ២,៣% ជាមធ្យម សម្រាប់ឆ្នាំ ២០២៣, ហើយនឹងវិលទៅរកនិន្នាការរយៈពេលវែងវិញ ក្នុងអត្រា ៣,០% ក្នុងឆ្នាំ ២០២៤ ដោយសារភាពស្រាកស្រាន្តនៃកត្តាតម្លៃទំនិញ ។ ចំណែកឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងរួមតូចមកត្រឹម -២,១% នៃកំណើនផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០២៣ ដោយសារការថយចុះនូវការនាំចូលមាស ការងើបឡើងវិញនៃវិហ្សូរទេសចរណ៍ និង កំណើនរឹងមាំនៃការនាំចេញផលិតកម្មកម្មន្តសាលមិនមែនកាត់ដេរ ។ បើទោះបីជាសម្ទុះនៃកំណើនសេដ្ឋកិច្ច ឆ្នាំ ២០២៣ នៅល្អក្តី, ហានិភ័យចម្បងមួយចំនួនក៏មាននឹងអាចជះឥទ្ធិផលដល់កំណើននេះ ដែលរួមមានដូចជា÷ ១. ភាពកាន់តែថមថយនូវតម្រូវការពីដៃគូពាណិជ្ជកម្មប្រទេសអភិវឌ្ឍន៍, ២. ផលជះឥទ្ធិពលនៃភាពថមថយសេដ្ឋកិច្ចចិន, ៣. ឥទ្ធិពលលើសពីការរំពឹងទុកនៃការរឹត

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

បន្ទឹងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក, ៤. ការកើនឡើងសម្ពាធបំណុល និង ៥. ការបន្តនូវភាពបែកខ្ញែកទីតាំងភូមិសាស្ត្រសេដ្ឋកិច្ច-នយោបាយ ។

ជាមួយគ្នានេះ, ក្រុមបេសកកម្ម Article IV ក៏បានផ្តល់អនុសាសន៍វិធានការ និងគោលនយោបាយចាំបាច់មួយចំនួន ជាពិសេសគោលនយោបាយចម្រុះ (policy mix) រវាង គោលនយោបាយសារពើពន្ធ, គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់, និង ការកែទម្រង់ជារចនាសម្ព័ន្ធ (structural reforms) ។ ក្នុងន័យនេះ, ការដាក់ចេញ និងធានានូវការអនុវត្តប្រកបដោយប្រសិទ្ធភាព និងតុល្យភាពនៃវិធានការអន្តរាគមន៍ រួមទាំងគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាល សំដៅលើកស្ទួយជីវភាពប្រជាជន ក៏ដូចជាសង្គម-សេដ្ឋកិច្ច ខណៈសេដ្ឋកិច្ចហ៊ុមព័ទ្ធទៅដោយហានិភ័យនេះ គឺកាន់តែមានសារៈសំខាន់សម្រាប់ការបន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យវិលទៅរកកំណើនសក្តានុពលវិញ ។

សម្រាប់រយៈពេលមធ្យមខាងមុខ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថានឹងមានកំណើនក្នុងរង្វង់ ៦,៥% ប៉ុន្តែលទ្ធភាពនៃការសម្រេចបាននូវកំណើនសក្តានុពលនេះ គឺចាំបាច់ត្រូវពឹងផ្អែកលើការពង្រឹង និងពន្លឿនការងារកែទម្រង់ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានធ្វើការវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃការវាយតម្លៃរបស់ក្រុមបេសកកម្ម Article IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ លើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដោយកត់សម្គាល់ពីកម្រិតស្រដៀងគ្នានៃការវាយតម្លៃតួលេខកំណើនជារួម ក្នុងឆ្នាំ ២០២៣ និងរយៈពេលមធ្យមខាងមុខ និងបានគូសបញ្ជាក់អំពីបញ្ហាប្រឈម និងហានិភ័យនៃសេដ្ឋកិច្ចសកលនាបច្ចុប្បន្ន និងរយៈពេលខាងមុខ ដែលតម្រូវឱ្យមានការតាមដានជាប្រចាំ សំដៅឆ្លើយតបទៅនឹងស្ថានភាពប្រែប្រួលយ៉ាងឆាប់រហ័សនេះ ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាល បាននិងកំពុងដើរលើមាគ៌ាដ៏សមស្របមួយ តាមរយៈការបន្តដាក់ចេញ និងអនុវត្តវិធានការអន្តរាគមន៍ ក៏ដូចជាគោលនយោបាយគាំទ្រផ្សេងៗយ៉ាងហ្មត់ចត់ សំដៅកាត់បន្ថយផលប៉ះពាល់ដែលនៅបន្សល់ពីវិបត្តិជំងឺកូវីដ-១៩ ផង ក៏ដូចជាហានិភ័យ និងបញ្ហាប្រឈមដែលបណ្តាលមកពីភាពមិនអំណោយផលនៃកត្តាភូមិសាស្ត្រនយោបាយផង ឱ្យសម្រេចបាននូវប្រសិទ្ធភាពក្នុងកម្រិតអតិបរមា សំដៅធានានូវការងើបឡើងវិញនៃសកម្មភាពសង្គម-សេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលក៏កំពុងពង្រឹងគោលនយោបាយសារពើពន្ធ ដោយពង្រឹងប្រសិទ្ធភាពថវិកា ដោយបន្តអនុវត្តកៀរគរចំណូលឱ្យប្រសើរឡើង, ពង្រីកវិស័យ និងប្រសិទ្ធភាពចំណាយ និងបន្តភាពប្រុងប្រយ័ត្នលើការគ្រប់គ្រងបំណុល ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ IMF ដែលបានផ្តល់អនុសាសន៍ល្អៗសម្រាប់ជាធាតុចូលដ៏មានសារៈសំខាន់គាំទ្រ ដល់ការគណនាកំណើនផលិតផលក្នុងស្រុកសរុប ផ្អែកលើឆ្នាំគោលថ្មី (២០១៨), ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) និងការរៀបចំគោលនយោបាយផ្សេងៗទៀត ឱ្យកាន់តែប្រសើរឡើងបន្ថែមលើការគិតគូរប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ និងច្បាស់លាស់ពីរាជរដ្ឋាភិបាលលើការអនុវត្តគោលនយោបាយអន្តរាគមន៍ខ្លី មធ្យម និងវែង ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ IMF ដែលតែងតែផ្តល់ជាជំនួយបច្ចេកទេស និងពង្រឹងសមត្ថភាព ដល់មន្ត្រីបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាគាំទ្រដល់សកម្មភាពសង្គម-សេដ្ឋកិច្ច រួមចំណែកតម្រង់ទិស និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ។

៚៚៚*៙៙៙